ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧០. អនក្រ. បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើនប្រសិទ្ធភាពការងារ
# របស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០៨០៧/០២៤ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧ ប្រកាសអោយប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជម្រះក្តី

-បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ចុះថ្ងៃ ទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងយុត្តិធម៌

-យោងតាមសំណើរបស់សហប្រធាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីយន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អំពីតួនាទី ភារកិច្ចនិងសមាសភាពព្រមទាំងដំណើរការនៃយន្តការនេះក្នុងគោលបំណងជួយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការបំពេញតួនាទីរបស់ខ្លួន ជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចចាត់ការតាមនីតិវិធី ស៊ើបអង្កេត ស្រាវជ្រាវ និងដាក់ឬមិនដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ជំពូកទី ២
## យន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា ២.-**

ត្រូវបានបង្កើតយន្តកាមួយនៅតុលាការកំពូលមានឈ្មោះថា ក្រុមជំនួយការក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមការដឹកនាំនិងបញ្ជាផ្ទាល់ពីប្រធានតុលាការកំពូល ឬ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដែលជាប្រធានក្រុមប្រឹក្សាវិន័យអាស្រ័យទៅតាមករណីទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា។

# ជំពូកទី ៣
# តួនាទី ភារកិច្ច និងសមាសភាព
# របស់ក្រុមជំនួយការក្រុមប្រឹក្សាវិន័យ

**មាត្រា ៣.-**

ក្រុមជំនួយការក្រុមប្រឹក្សាវិន័យមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

-ទទួលពាក្យបណ្តឹងនិងតាមដានព័ត៌មានទាំងឡាយពាក់ព័ន្ធទៅនឹងចៅក្រម ព្រះរាជអាជ្ញា និង រាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ចុះធ្វើអធិការកិច្ចជាប្រចាំស្វែងយល់អំពីការលំបាក ការងាយស្រួល ការអនុវត្តន៍ក្រមសីលធម៌វិជ្ជាជីវៈ និង ណែនាំអំពីចំណុចខ្វះខាតដែលកំពុងកើតមានច្រើននៅតាមតុលាការនានា និងធ្វើរបាយការណ៍ លើក សំណើវិធានការជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចាត់ការជាបន្ត

-ចុះស៊ើបអង្កេតករណីមិនប្រក្រតីតាមបណ្តាសាលាជម្រះក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមពាក្យបណ្តឹង របស់ក្រសួងយុត្តិធម៌ សាមីខ្លួននិងស្ថាប័ននានា

-ធ្វើរបាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យដោយលើកនូវអង្គហេតុ អង្គច្បាប់ និងធាតុចេតនា របស់ ចៅក្រមឬព្រះរាជអាជ្ញា ស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រេចរបស់ចៅក្រម ព្រះរាជអាជ្ញា នោះនិងលើកមតិដោះស្រាយ

-ចាត់ការឲ្យថតចម្លងឯកសារដែលពាក់ព័ន្ធនឹងចៅក្រមឬព្រះរាអាជ្ញា ដែលត្រូវគេប្តឹងជូនសមាជិកក្រុមប្រឹក្សា វិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ធ្វើទំនាក់ទំនងផ្នែករដ្ឋបាលជាមួយក្រសួងយុត្តិធម៌ និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត

-រៀបចំរាល់កិច្ចប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើកំណត់ហេតុអង្គប្រជុំ គ្រប់គ្រង ឯកសារ និងពាក្យបណ្តឹងនានា

-ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុម ប្រឹក្សានៃអង្គចៅក្រម

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រគល់ឱ្យ។

**មាត្រា ៤.-**

ក្រុមជំនួយការក្រុមប្រឹក្សាវិន័យមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **គង់ ស្រ៊ឹម** | អនុប្រធានតុលាការកំពូល | ប្រធាន |
| ២-ឯកឧត្តម**ឈួន ចាន់ថា** | អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល | អនុប្រធាន |
| ៣-ឯកឧត្តម **ប៊ុន ហុន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៤-លោក **ឌី ណោខ** | ចៅក្រមតុលាការកំពូល | សមាជិក |
| ៥-លោក **សាលី ធារ៉ា** | ចៅក្រមតុលាការកំពូល | សមាជិក |
| ៦-លោក **ស៊ឹម បញ្ញាឧត្តម** | ចៅក្រមតុលាការកំពូល | សមាជិក |
| ៧- លោក **អ៊ីច គីមស្រ៊ី** | ចៅក្រមតុលាការកំពូល | សមាជិក |

| | | |
|---|---|---|
| ៨-លោក **ជ័យ សុផល** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | សមាជិក |
| ៩-លោក **ផាន់ ចន្ទ្ណារ័ត្ន** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | សមាជិក |
| ១០-លោក **ចាន់ តារាវស្នី** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | សមាជិក |
| ១១-លោក **សេខ ម៉ុនឃាខ** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | លេខាធិការ |

ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ក្រុមជំនួយការក្រុមប្រឹក្សាវិន័យដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រើប្រាស់នូវមន្ត្រីដូចខាងក្រោមជាជំនួយការៈ

១-មន្ត្រីរដ្ឋបាលតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

២-មន្ត្រីនគរបាលយុត្តិធម៌ដែលជានគរបាលជាតិ កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចនៃ ក្រសួងស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី ៤
## ដំណើរការនៃក្រុមជំនួយការក្រុមប្រឹក្សាវិន័យ

**មាត្រា ៥**.-

ក្រុមជំនួយការក្រុមប្រឹក្សាវិន័យបើកការប្រជុំរបស់ខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះអញ្ជើញ។

ក្រុមជំនួយការក្រុមប្រឹក្សាវិន័យមានសិទ្ធិអញ្ជើញមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា ៦**.-

ក្រសួងយុត្តិធម៌ និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងករណីពិនិត្យឃើញកំហុសឆ្គងរបស់ចៅក្រម ឬព្រះរាជអាជ្ញាត្រូវប្តឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីដោះស្រាយឱ្យទាន់ពេលវេលាប្រកបដោយយុត្តិធម៌និងតម្លាភាព។

**មាត្រា ៧**.-

ក្រុមជំនួយការក្រុមប្រឹក្សាវិន័យមានសិទ្ធិប្រើប្រាស់ត្រារបស់តុលាការកំពូលឬមហាអយ្យការអមតុលាការកំពូលទៅតាមមុខការ។

**មាត្រា ៨**.-

ថវិកាសម្រាប់ដំណើរការការងាររបស់ក្រុមជំនួយការក្រុមប្រឹក្សាវិន័យជាបន្ទុកថវិការបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវកាត់បម្រុងមួយផ្នែកតាមទំហំជាក់ស្តែងនៃការងារ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា៤ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**សុខ អាន**
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ឌិត មុន្ទី**
ប្រធានតុលាការកំពូល

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- សាលាឧទ្ធរណ៍ ✓
- សាលាដំបូងរាជធានី-ខេត្ត
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ